រៀបចំដោយ

គាំទ្រដោយ

ព្រឹត្តិបត្រពាណិជ្ជកម្ម
iTrade Bulletin

Inside
infographic

Policy Brief:
Geo-economic Fragmentation and Resilience of Global Product on Value Chains in East Asia and ASEAN

Shandre Mugan Thangavelu
Jeffrey Cheah Institute for Southeast Asia, Sunway University

ភ្នំល ០១ | លេខ ០៦ | ខែ កញ្ញា ឆ្នាំ២០២៥
VOLUME 01 | ISSUE 06 | SEPTEMBER 2025


ការស្វែងយល់អំពី ផ្នែកទី១
សក្តានុពលផលិតផលស្រូវ និងអង្ករនៅកម្ពុជា

រៀបចំដោយ | គាំទ្រដោយ


សូមស្កេនដើម្បីទាញយក
ព្រឹត្តបត្រពាណិជ្ជកម្ម
** ព័ត៌មានបន្ថែម
សូមទាក់ទងមកកាន់លេខទូរស័ព្ទ
ទំនាក់ទំនងសាធារណៈ ១២៦៦

I.ព័ត៌មានមូលដ្ឋាន នៃស្រូវ និងអង្ករ (កូដទំនិញ:១០០៦)


ការនាំចូលស្រូវ និងអង្ករ (កូដទំនិញ: ១០០៦)សម្រាប់ទីផ្សារពិភពលោក




ការនាំចូលស្រូវ និងអង្ករ (កូដទំនិញ: ១០០៦) ក្នុងឆ្នាំ(២០២៤) មានទឹកប្រាក់សរុប ចំនួន ៣៨,៩៣ ប៊ីលានដុល្លារ




១.ប្រទេសកំពូលទាំង៥ សម្រាប់ការនាំចូលអង្ករស្រិតបានពាក់កណ្តាល ឬស្រិតហើយទាំងស្រុង(កូដទំនិញ: ១០០៦៣០)លើទីផ្សារពិភពលោក (២០២៤)



អត្រាពន្ធគយ នៃអង្ករស្រិតបានពាក់កណ្តាល ឬស្រិតហើយទាំងស្រុង សម្រាប់ការនាំចូល(កូដទំនិញ: ១០០៦៣០)



អង្ករស្រិតបានពាក់កណ្តាល ឬស្រិតហើយទាំងស្រុង





II.ចំណុចសំខាន់ៗ នៃឧស្សាហកម្មស្រូវនិងអង្ករ កម្ពុជា (២០២៤)

កម្ពុជាគឺជាប្រទេសផលិតស្រូវធំជាងគេទី១០ របស់ពិភពលោកនិង ជាប្រទេសដែលនាំចេញស្រូវ(កូដទំនិញ: ១០០៦១០)ធំជាងគេទី១ របស់ពិភពលោក ហើយក៏ជាប្រទេសនាំចេញអង្ករស្រិតបាន ពាក់កណ្តាល ឬស្រិតហើយទាំងស្រុង (កូដទំនិញ: ១០០៦៣០) ធំជាងគេទី៩ របស់ពិភពលោកនៅឆ្នាំ(២០២៤)

កម្ពុជាបានឈ្នះពានរង្វាន់អង្ករល្អបំផុតរបស់ពិភពលោក២០១២, ២០១៣, ២០១៤, ២០១៨, និង ២០២២ ក្នុងសន្និសីទស្រូវអង្ករ



ផលិតកម្ម
១៣,៨៩ លានតោន/ឆ្នាំ

ផ្ទៃដីដាំដុះ
៣,៨៦ លានហិកតា

អតិរេកស្រូវ
លើសពី ៧ ទៅ ៨ លានតោន/ឆ្នាំ

ការនាំចេញអង្ករ
៦៥១.០០០តោន (ធ្លាក់ចុះ -0,៧%) ប្រាក់ចំណូល ពីការនាំចេញ៖ ៤៩១ លានដុល្លារ(កើនឡើង+ ៥,៣%)(២០២៤)


ការស្វែងយល់អំពី ផ្នែកទី២
សក្តានុពលផលិតផលស្រូវ និងអង្ករនៅកម្ពុជា

ការនាំចេញស្រូវ៖ ៥,១ លានតោន
ប្រាក់ចំណូលពីការនាំចេញ៖ ១.៤៩៦ លានដុល្លារ (២០២៤)

តម្លៃនៃការនាំចេញគិតជាមធ្យម
អង្ករ៖ ៧១៥,៨២ ដុល្លារ/តោន ស្រូវ៖ ២៩៣,៣៣ ដុល្លារ/តោន

កម្ពុជានាំចេញស្រូវទៅកាន់វៀតណាម
(លើសពី៩៥% នៃការនាំចេញស្រូវសរុប)

ប្រទេសកំពូលទាំង៥ ដែលនាំចូលអង្ករស្រិតបានពាក់កណ្តាល ឬស្រិតហើយទាំងស្រុង(កូដទំនិញ: ១០០៦៣០) ពីកម្ពុជានៅឆ្នាំ២០២៤



សក្តានុពលនៃការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសដទៃ (ការប៉ាន់ស្មានសម្រាប់ឆ្នាំ ២០២៩)

ប្រទេស	សក្តានុពលនៃការនាំចេញ	ការនាំចេញបាន	សក្តានុពលនៃការនាំចេញនៅសល់
	អង្ករស្រិតបានពាក់កណ្តាល ឬស្រិតហើយទាំងស្រុង(កូដទំនិញ: ១០០៦៣០)(ដុល្លារ)		
ឥណ្ឌូនេស៊ី	១០ លាន	៣,១ លាន	៧,៣ លាន
ហ្វីលីពីន	២០ លាន	៦៩៦ ៣ន់	១៩ លាន
អារ៉ាប៊ីសាអូឌីត	៦,១ លាន	៤,៦ លាន	១,៥ លាន
សហរដ្ឋអាមេរិក	៤៧ លាន	១,៤ លាន	៤៦ លាន

រៀបចំដោយ

គាំទ្រដោយ

ប្រភព៖ ១. ITC(Trademap). Retrieved August 05, 2025 from (https://www.trademap.org)
២.ASEAN Tariff Finder(https://asean.mendel-online.com/)
៣. ក្រសួងកសិកម្មសហរដ្ឋអាមេរិក (https://www.fas.usda.gov/data/production/commodity/0422110)

III.គំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល

១.ក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រ

▶យុទ្ធសាស្ត្រស្តីពីការពង្រីកទីផ្សារ និងពិពិធកម្មការនាំចេញអង្ករកម្ពុជា ឆ្នាំ២០២៥-២០៣០៖

▶គោលដៅ៖ "ដើម្បីសម្រេច បានការនាំចេញអង្ករមួយលានតោនតាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយតួអង្គខ្សែច្រវាក់តម្លៃអង្ករជាយុទ្ធសាស្ត្រ"

▶វិធានការយុទ្ធសាស្ត្រ៖

- ១. ការពង្រឹងការស្រាវជ្រាវផ្នែកទីផ្សារ ដើម្បីជួយជំរុញការនាំចេញអង្ករប្រកបដោយប្រសិទ្ធភាព
- ២. ការលើកកម្ពស់លទ្ធភាពទទួលបានទីផ្សារសម្រាប់សំហូរពាណិជ្ជកម្មអង្ករដោយរលូន
- ៣. ការពង្រឹងម៉ាកយីហោ និងការផ្សព្វផ្សាយផលិតផលអង្ករកម្ពុជា
- ៤. ការលើកកម្ពស់សមត្ថភាពរបស់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករ
- ៥. ការពង្រឹងសមត្ថភាពនាំចេញរបស់សហគ្រាសពាណិជ្ជកម្មកម្ពុជាសម្រាប់ការផ្គត់ផ្គង់ទ្រង់ទ្រាយធំ
- ៦. ការទទួលយកដំណោះស្រាយផ្នែកលើទីផ្សារ ដើម្បីលើកកម្ពស់ខ្សែច្រវាក់តម្លៃអង្ករបស់កម្ពុជា

▶ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០៖

- • ការបង្កើនទិន្នផលស្រូវ និងកាត់បន្ថយការខាតបង់ក្រោយការប្រមូលផល
- • ការពង្រឹងខ្សែច្រវាក់តម្លៃស្រូវ (ពីកសិដ្ឋានរហូតដល់ការនាំចេញ)
- • ការលើកកម្ពស់ការអនុវត្តកសិកម្មដែលធន់នឹងអាកាសធាតុ

▶គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (២០១០)

- • មានគោលបំណងជំរុញការនាំចេញអង្ករ បង្កើនប្រាក់ចំណូលដល់កសិករ និងពង្រីកចំណែកទីផ្សារអង្ករកម្ពុជាលើពិភពលោក

សម្គាល់៖ការធ្វើពិពិធកម្មទីផ្សារអង្ករ និងផលិតផលអង្ករ(មេ្សាអង្ករ និងមេ្សា, មី និងប៉ាស្តា, អាហារសម្រន់, ស្រាចេញពីអង្ករ, ប្រេងកន្ទក់ និងផលិតផលសុខភាព) ជាយុទ្ធសាស្ត្រយូរអង្វែងសម្រាប់រក្សាចេរភាពថ្លៃ និងបង្កើនតម្លៃបន្ថែម

៤.របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៤ និងទិសដៅឆ្នាំ២០២៥ ទំព័រ៧
៥. យុទ្ធសាស្ត្រស្តីពីការពង្រីកទីផ្សារ និងពិពិធកម្មការនាំចេញអង្ករកម្ពុជា ឆ្នាំ២០២៥-២០៣០
៦. របាយការណ៍សហព័ន្ធស្រូវអង្ករកម្ពុជា (https://www.information.gov.kh/articles/149120)
៧. ITC(Trademap) (Export Potential Map) RetrievedAugust 20, 2025 from (https://exportpotential.intracen.org/en/)

សូមស្កេនដើម្បីទាញយក ព្រឹត្តបត្រពាណិជ្ជកម្ម

** ព័ត៌មានបន្ថែម
សូមទាក់ទងមកកាន់លេខទូរស័ព្ទទំនាក់ទំនងសាធារណៈ: ១២៦៦

EXPLORING THE POTENTIAL OF PADDY AND RICE IN CAMBODIA Part1

Organized by


Supported by

Scan to access iTrade Bulletin


** For more imformation, please contact the Ministry of Commerce Call center 1266

I. BASIC INFORMATION OF PADDY AND RICE (HS CODE: 1006)


Imports of paddy and rice (HS code: 1006) for the world maket




Paddy and rice imports (HS code: 1006) USD 38.93 Billion in (2024)




Top 5 countries for importing semi-milled or whole rice (HS code: 100630) on the world market (2024)



Tariff Rates of semi-milled or whole rice for import (HS code: 100630)



SEMI-MILLED OR WHOLE RICE





II. KEY HIGHLIGHTS OF CAMBODIA'S PADDY AND RICE INDUSTRY (2024)

Cambodia is the world's 10th largest rice producer and the world's 1st largest paddy exporter (HS code: 100610), and the world's 9th largest exporter of semi-milled or whole rice (HS code: 100630) in 2024.

Cambodia won the World's Best Rice 2012, 2013, 2014, 2018, and 2022 Award in World Rice Conference (WRC)



PRODUCTION
13.89 Million Tons/year

CULTIVATED AREA
3.86 Million hectares

PADDY SURPLUS
over 7 to 8 million tons/year

RICE EXPORTS
651,000 tons (down -0.7%) Export revenue: USD 491 million (up +5.3%) (2024)

EXPLORING THE Part2


POTENTIAL OF PADDY AND RICE IN CAMBODIA

PADDY EXPORTS
5.1 million tons, export revenue USD 1,496 million (2024)

AVERAGE EXPORT PRICE
Rice:715.82 USD/Ton, Paddy:293.33 USD/Ton

CAMBODIA EXPORTS PADDY TO VIETNAM
(over 95% of total paddy exports)

TOP 5 COUNTRIES IMPORTING SEMI-MILLED OR WHOLE RICE (COMMODITY CODE: 100630) FROM CAMBODIA IN 2024



Potential for Cambodia's export to other countries (Estimate for 2029)

COUNTRIES	semi-milled or whole rice (HS code: 100630) (USD)		
	Export potential	Baseline exports	Unrealized potential remaining
Indonesia	10 Million	3.1 Million	7.3 Million
Philippines	20 Million	696 Thousand	19 Million
Saudi Arabia	6.1 Million	4.6 Million	1.5 Million
United States of America	47 Million	1.4 Million	46 Million

Organized by

Supported by

Source: 1. ITC(Trademap). Retrieved August 05, 2025 from(https://www.trademap.org)
2.ASEAN Tariff Finder(https://asean.mendel-online.com/)
3. U.S. Department of Agriculture (https://www.fas.usda.gov/data/production/commodity/0422110)

III. ROYAL GOVERNMENT INITIATIVES

A. POLICY & STRATEGIC FRAMEWORKS

▶ **CAMBODIA'S MILLED RICE MARKET EXPANSION AND EXPORT DIVERSIFICATION STRATEGY 2025–2030:**

▶ **GOAL:** "To achieve one million tons milled rice export through working in close collaboration with strategic rice value chain actors."

▶ **STRATEGIC MEASURES:**

1. Strengthening market intelligence for effective rice export
2. Enhancing market access for boosting milled rice export performance
3. Leveraging branding and promotion of Cambodia rice products
4. Enhancing the export capacity of rice exporters and millers
5. Enhancing the export capacity of Cambodia Trade Enterprise for large-scale supply
6. Adopting market-based solutions for Cambodia's rice value chain improvement

▶ **STRATEGIC DEVELOPMENT PLAN FOR CAMBODIAN AGRO-Industries (2019-2030):**

- Increasing paddy yields and reducing post-harvest losses.
- Strengthening rice value chains (from farm to export).
- Promoting climate-resilient farming practices.

▶ **POLICY ON THE PROMOTION OF PADDY PRODUCTION AND RICE EXPORT (2010)**

- Aims to promote rice exports, improve farmer incomes, and enhance Cambodia's global rice market position.

Note: Diversifying rice markets and rice products (riceflour and starch, noodles and pasta, rice snacks,rice wine, bran oil, and health prod ucts) is along-term strategy for price stability and addedvalue growth.

4. Summary report on agriculture, forestry, and fisheries work in 2024 and targets for 2025, page 7
5. Cambodia's Milled Rice Market Expansion andExport Diversification Strategy 2025–2030
6. Report from the Cambodia Rice Federation (https://www.information.gov.kh/artcles/149120)
7. ITC(Trademap) (Export Potential Map) RetrievedAugust 20, 2025 from (https://exportpotential.intracen.org/en/)

Scan to access iTrade Bulletin

**** For more imformation, please contact the Ministry of Commerce Call center 1266**

ក្រសួងពាណិជ្ជកម្ម ពិនិត្យរបៀបវារៈពាណិជ្ជកម្មសំខាន់ៗ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច

ក្រសួងពាណិជ្ជកម្ម បានបើកកិច្ចប្រជុំមួយ ដើម្បីពង្រឹងការអនុវត្តពាណិជ្ជកម្ម បង្កើនប្រសិទ្ធភាពរដ្ឋបាល និងវាយតម្លៃវឌ្ឍនភាពពាណិជ្ជកម្មក្នុងស្រុក និងអន្តរជាតិ សំដៅធានាឱ្យស្របតាមរបៀបវារៈនៃការស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល។ យោងតាមសេចក្តីប្រកាសរបស់ក្រសួងពាណិជ្ជកម្ម កិច្ចប្រជុំនេះត្រូវបានធ្វើឡើងទាំងដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូអនឡាញ ដោយគ្របដណ្តប់លើទិដ្ឋភាពសំខាន់ៗមួយចំនួន រួមមានកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មក្នុងតំបន់ ការធ្វើបច្ចុប្បន្នភាពរដ្ឋបាល និងហិរញ្ញវត្ថុ ការអនុវត្តពាណិជ្ជកម្មក្នុងស្រុក គំនិតផ្តួចផ្តើមជំរុញពាណិជ្ជកម្ម ការអភិវឌ្ឍកម្មសិទ្ធិបញ្ញា វឌ្ឍនភាពពាណិជ្ជកម្មខេត្ត និងការចូលរួមពាណិជ្ជកម្មអន្តរជាតិ។ *ប្រភព៖ Khmer Times*

ក្រុមហ៊ុននាំចេញអង្ករសម្លឹងមើលឱកាសពង្រីកទីផ្សារក្នុងពិព័រណ៌ពាណិជ្ជកម្មនៅប្រទេសអាល្លឺម៉ង់

សហព័ន្ធស្រូវអង្ករកម្ពុជា បានឱ្យដឹងថាក្រុមហ៊ុននាំចេញចំនួន១៣នឹងដាក់តាំងបង្ហាញផលិតផលរបស់ខ្លួននៅក្នុងពិព័រណ៌ម្ហូបអាហារ ANUGA ២០២៥ ក្រោមពន្លារបស់សហព័ន្ធស្រូវអង្ករកម្ពុជា។ វិធានការនេះធ្វើឡើងដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈកិច្ចសហការគាំទ្រពីសហគ្រិនខ្មែរនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។ ប្រភពដដែលបានបន្តថា "គោលបំណងនៃការចូលរួមក្នុងការតាំងពិព័រណ៌នេះគឺដើម្បីរួមចំណែកដល់ការធ្វើពិពិធកម្មយុទ្ធសាស្ត្រទីផ្សារ"។ គោលបំណងនេះគឺ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយគោរពតាមស្តង់ដានិងតម្រូវការសុវត្ថិភាពចំណីអាហារ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាកត្តាជំរុញដ៏សំខាន់ក្នុងការលើកកម្ពស់លទ្ធភាពទទួលបានទីផ្សារសម្រាប់ផលិតផល និងជំរុញការដាំដុះតាមទីផ្សារ។

ប្រភព៖ Khmer Times

ការនាំចេញក្រោមកិច្ចព្រមព្រៀងអាសិបមានចំនួនជាង៦,៦ ប៊ីលានដុល្លារ

ការនាំចេញទំនិញពីកម្ពុជាទៅកាន់បណ្តាប្រទេសសមាជិកនៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(អាសិប) ក្នុងរយៈពេល ៨ខែឆ្នាំ២០២៥ មានទឹកប្រាក់ជាង ៦,៦ ប៊ីលានដុល្លារ កើតឡើងជិត ១០% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ នេះបើយោងតាមក្រសួងពាណិជ្ជកម្ម។ ទិន្នន័យបានបង្ហាញថា ចន្លោះពីខែមករា ដល់ខែសីហា ឆ្នាំ២០២៤ កម្ពុជាបាននាំចេញទំនិញទៅបណ្តាប្រទេសសមាជិកអាសិប ក្នុងទឹកប្រាក់សរុប ៦,៦៣ ប៊ីលានដុល្លារ កើនឡើង ៩,៥% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២៤។ សមាជិកអាសិបដែលទទួលទិញទំនិញពីកម្ពុជាច្រើនជាងគេ គឺវៀតណាម ចិន ជប៉ុន ថៃ និងកូរ៉េខាងត្បូង។ *ប្រភព៖ Phnom Penh Post*

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម លើកឡើងពីភាពរីកចម្រើននៃពាណិជ្ជកម្មឌីជីថល

ក្រសួងពាណិជ្ជកម្មបាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រពាណិជ្ជកម្មឌីជីថល ដែលជាផ្នែកមួយនៃផែនការរបស់ខ្លួនក្នុងការរួមចំណែកក្នុងការកសាងមូលដ្ឋានគ្រឹះសេដ្ឋកិច្ចដ៏រឹងមាំសម្រាប់កម្ពុជា។ លើសពីនេះ ក្រសួងកំពុងអនុវត្តសេវាកម្មសាធារណៈសំខាន់ៗជាច្រើនលើអ៊ីនធឺណិត និងតាមរយៈវេទិកាស្វ័យប្រវត្តិកម្ម។ តាមការព្យាករណ៍ ពាណិជ្ជកម្មអេឡិចត្រូនិករបស់កម្ពុជានឹងកើនដល់ ១,១ប៊ីលានដុល្លារនៅឆ្នាំ២០២៥។ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងបានថ្លែងក្នុងពិធីបើកវេទិកាពាណិជ្ជកម្មឌីជីថលកម្ពុជា និងពិព័រណ៌អនឡាញ លើកទី២ ក្រោមប្រធានបទ "កសាងអនាគតកម្ពុជាតាមរយៈពាណិជ្ជកម្មឌីជីថល" ដែលវេទិកានេះមានគោលបំណងជំរុញការអភិវឌ្ឍពាណិជ្ជកម្មឌីជីថលនៅកម្ពុជា។ លោកជំទាវបានបន្ថែមថា " កន្លងមកយើងសង្កេតឃើញថា វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាបានបង្ហាញនូវភោពធន់ និងភាពប៉ិនប្រសព្វរបស់ប្រជាជនកម្ពុជា។ តាមការព្យាករណ៍នៅចុងឆ្នាំនេះ(២០២៥) ចំណូលពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវរំពឹងថា នឹងឈានដល់ ១,១ ប៊ីលានដុល្លារ ហើយនៅក្នុងឆ្នាំ២០២៩ នឹងឈានទៅដល់ ១,៨ ប៊ីលានដុល្លារ"។ *ប្រភព៖ Phnom Penh Post*

Moc Reviews Key Trade Agenda to Boost Economic Growth

The Ministry of Commerce (MoC) held a meeting to strengthen trade performance, enhance administrative efficiency, and evaluate progress in domestic and international commerce, aiming to ensure alignment with the Royal Government's economic recovery and development agenda. According to the MoC announcement, the meeting was held both in person and via video conference, covering several key aspects, including regional trade cooperation, administrative and financial updates, domestic trade performance, trade promotion initiatives, intellectual property development, provincial commerce progress, and international commercial engagement. ***Source: Khmer Times***

Rice Exporters Eye Opportunities to Expand Market at German Trade Fair

The Cambodia Rice Federation said on Thursday that 13 exporting companies are going to showcase their products at the ANUGA 2025 food exhibition under the pavilion of the Cambodia Rice Federation. This move is made with support from the Cambodian Government via the co-support of the Khmer Enterprise (KE) of the Ministry of Industry, Science, Technology & Innovation; and Agricultural and Rural Development Bank (ARDB), it stated. "The objective of participating in this exhibition is to contribute to the market diversification strategy," it said. This objective is aligned with the Royal Government's policy; the Ministry of Industry, Science, Technology, and Innovation, with regard to food safety standards and requirements, and the Ministry of Agriculture, Forestry and Fisheries as the key drivers in promoting market access for products and fostering market-oriented cultivation. ***Source: Khmer Times***

RCEP Exports Climb Almost 10% Jan-Aug; Pass $6.5B

Cambodian exports to the member countries of the Regional Comprehensive Economic Partnership (RCEP) totalled over $6.6 billion during the first eight months of 2025, an increase of nearly 10% compared to the same period in 2024, according to the Ministry of Commerce. From January to August 2025, Cambodia exported goods worth $6.63 billion to RCEP members, a 9.5% increase over the same period in 2024. The top buyers of Cambodian products among RCEP members were Vietnam, China, Japan, Thailand and South Korea. ***Source: Phnom Penh Post***

Commerce Minister Highlights Growth of Digital Trade

The Ministry of Commerce is currently drafting a Digital trade Strategy, as part of its plans to contribute to building a stronger economic foundation for Cambodia. In addition, it is implementing a variety of essential public services online and through automated platforms. It is projected that Cambodia's electronic commerce will reach $1.1 billion by 2025. Commerce minister Cham Nimul addressed the September 12 opening ceremony of the 2nd Digital Trade Forum (DTF) in Phnom Penh. Themed "Advancing Cambodia's Future through Digital Trade", the forum aims to foster the development of digital trade in Cambodia. "We have seen the resilience and adaptability of Cambodians in this sector. By the end of 2025, e-commerce revenue is expected to reach $1.1 billion, and by 2029, it is projected to reach $1.8 billion," she added. ***Source: Phnom Penh Post***

ពន្ធគយមានការរំខាន 'មិនធ្លាប់មាន' ចំពោះច្បាប់ពាណិជ្ជកម្មសកល

អគ្គនាយិកា អង្គការពាណិជ្ជកម្មពិភពលោក (WTO) លោកស្រី Ngozi Okonjo-Iweala មានប្រសាសន៍ថា ទំហំពាណិជ្ជកម្មសកលក្រោមលក្ខខណ្ឌរបស់ WTO បានធ្លាក់ចុះមកត្រឹម ៧២% ពីប្រហែល ៨០% ដែលជាការរំខានដ៏ធំបំផុតចាប់តាំងពីសង្គ្រាមលោកលើកទី២ ។ លោកស្រីបានព្រមានថាពន្ធគយអាចប៉ះពាល់ដល់ពាណិជ្ជកម្មដល់ឆ្នាំ២០២៦ នៅពេលដែលទំនិញដែលទិញស្តុកទុកខាងមុខអស់។ WTO បានបង្កើនការព្យាករណ៍កំណើនពាណិជ្ជកម្មរបស់ខ្លួនពីខែសីហា ពី ០,២% ទៅ ០,៩%។ លោកស្រីក៏បានសម្តែងការព្រួយបារម្ភចំពោះផែនការរបស់ អាម៉េរិក ក្នុងការកាត់បន្ថយមូលនិធិ ចំនួន ២៩លានដុល្លារនៅក្នុង WTO ទោះបីកិច្ចពិភាក្សានៅតែបន្តជាមួយតំណាងពាណិជ្ជកម្មអាម៉េរិក។ លោកស្រីបានលើកឡើងពីឱកាសសម្រាប់កំណែទម្រង់ WTO ដោយកត់សម្គាល់ពីភាពបើកចំហរបស់ប្រទេសចិនលើគោលនយោបាយឧស្សាហកម្ម។ សមាជិកកំពុងធ្វើការចរចាធ្វើឱ្យមានសម្រេចចិត្តក្នុង WTO និងដោះស្រាយការឧបត្ថម្ភធន។ *ប្រភព៖ REUTERS*

កិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផលរបស់ WTO បានចូលជាធរមាន

កិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផលរបស់ WTO បានចូលជាធរមាន ដោយសមាជិកបានប្តេជ្ញាចិត្ត ដើម្បីទប់ស្កាត់ការឧបត្ថម្ភធនដែលមានគ្រោះថ្នាក់ធ្វើឱ្យបាត់បង់ស្តុកជលផលសមុទ្រ។ កិច្ចព្រមព្រៀងនេះត្រូវបានអនុម័តនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១២ នៅខែមិថុនា ឆ្នាំ២០២២ ហាមឃាត់សកម្មភាពនេសាទសមុទ្រខុសច្បាប់ ពុំមានការរាយការណ៍ និងនេសាទជ្រុលហួសកម្រិត រួមទាំងការគ្រប់គ្រងពុំបានត្រឹមត្រូវ។ លោកស្រីអគ្គនាយិកា អិនហ្គូហ្ស៊ី អូកុនហ្សូ អ៊ីវេឡា បានសាទរថាវាជា "ចំណុចសំខាន់សម្រាប់អភិបាលកិច្ចពាណិជ្ជកម្មសកល" ដែលការពារជីវភាពរស់នៅ និងលើកកម្ពស់ចីរភាព។ ប្រទេសប្រេស៊ីល កេនយ៉ា វៀតណាម និងតុងហ្គា បានទទួលយកសំឡេងយល់ស្រប ដែលលើសពីកម្រិតពីរភាគបីនៃកិច្ចព្រមព្រៀងនេះ។ សមាជិកបានសន្យាដើម្បីការអនុវត្តកិច្ចព្រមព្រៀង បង្កើតមូលនិធិជលផលរបស់ WTO សម្រាប់ការកសាងសមត្ថភាព និងបង្កើតគណៈកម្មាធិការឧបត្ថម្ភធនលើវិស័យជលផលដើម្បីបង្កើន តម្លាភាព។ កិច្ចព្រមព្រៀងនេះមានគោលបំណងស្តារស្តុកជលផល សន្តិសុខស្បៀង និងគាំទ្រមនុស្សរាប់រយលានដែលពឹងផ្អែកលើជលផលសមុទ្រ។ *ប្រភព៖ WTO*

ឥណ្ឌូណេស៊ី និងសហភាពអឺរ៉ុប បញ្ចប់ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្ម បន្ទាប់ពីចរចា៩ឆ្នាំ

ឥណ្ឌូណេស៊ី និងសហភាពអឺរ៉ុបបានបញ្ចប់ការចរចាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (IEU-CEPA) បន្ទាប់ពី ការចរចារយៈពេល៩ឆ្នាំ ក្នុងគោលបំណងជំរុញពាណិជ្ជកម្ម និងការវិនិយោគ។ កិច្ចព្រមព្រៀងនេះបានលុបពន្ធនាំចូលលើ ៩៨.៥% នៃទំនិញសហភាពអឺរ៉ុប ទៅកាន់ប្រទេសឥណ្ឌូនេស៊ី និងអនុញ្ញាតឱ្យទំនិញឥណ្ឌូនេស៊ីទទួលបានពន្ធសូន្យនៅក្នុង ៩០% នៃទីផ្សារសហភាពអឺរ៉ុប។ វាជួយសម្រួលដល់នីតិវិធីនាំចូលសម្រាប់ផលិតផល សហភាពអឺរ៉ុប រួមមានរថយន្ត ម្សៅទឹកដោះគោ ឈីស សាច់ និងសូកូឡា។ ពាណិជ្ជកម្មរវាងឥណ្ឌូណេស៊ី និងសហភាពអឺរ៉ុបត្រូវបានគេរំពឹងថានឹងកើនឡើងទ្វេដងក្នុងរយៈពេល ប្រាំឆ្នាំដំបូង។ កិច្ចព្រមព្រៀងនេះអាចបង្កើនការវិនិយោគ និងកិច្ចសហប្រតិបត្តិការខ្សែច្រវាក់ផ្គត់ផ្គង់ រួមទាំងរ៉ែសំខាន់ៗ និងការផលិតរថយន្តអគ្គិសនី។ របាំងមិនមែនពន្ធ ដូចជាបទប្បញ្ញត្តិស្តីពីការកាប់បំផ្លាញព្រៃឈើរបស់សហភាពអឺរ៉ុប នៅតែជាបញ្ហាប្រឈមសម្រាប់ឧស្សាហកម្មប្រេងដូងរបស់ប្រទេសឥណ្ឌូនេស៊ី។ *ប្រភព៖ REUTERS*

ចិន-អាម៉េរិក៖ តើប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេទាំងពីររបស់ពិភពលោកអាចមានបញ្ហាខុសគ្នាបែបណា?

សហរដ្ឋអាម៉េរិក និងចិនប្រឈមមុខខុសគ្នាៗនឹងនិន្នាការចំណាយនៃការរស់នៅ, នៅក្នុងប្រទេសចិន "វដ្តនៃថ្លៃសាច់ជ្រូក" តម្រូវការសាច់ជ្រូក និងការផ្គត់ផ្គង់លើសតម្រូវការបានជំរុញឱ្យតម្លៃអាហារធ្លាក់ចុះ ដែលនឹងបណ្តាលឱ្យមានបរិត្តផរណា។ កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនការប្រើប្រាស់ រួមមានការចំណាយសុខុមាលភាព កម្មវិធីពាណិជ្ជកម្ម និងការកំណត់គោលដៅ

"សេដ្ឋកិច្ចប្រាក់"។ នៅសហរដ្ឋអាម៉េរិក ពន្ធគយបានបង្កើត "ការភ្ញាក់ផ្អើលនៃការផ្គត់ផ្គង់ជាប្រវត្តិសាស្ត្រ" បណ្តាលឱ្យការកើនឡើងនូវតម្លៃសម្រាប់គ្រឿងសង្ហារឹម គ្រឿងទេស រថយន្ត និងសម្លៀកបំពាក់ ដែលប៉ះពាល់ប្រាក់ចំណូលគ្រួសារ។ អាជីវកម្មឆ្លើយតបដោយការបញ្ចុះប្រាក់ឈ្នួល ការចម្រាញ្បុគ្គលិក ឬមិនជ្រើសរើសជំនួសបុគ្គលិក។ ពន្ធគយរបស់អាម៉េរិកមានគោលបំណងក្នុងការនាំការផលិតវិលត្រលប់ក្នុងស្រុកវិញ ប៉ុន្តែភាគច្រើនបង្កើនការចំណាយ។ ទន្ទឹមនឹងនេះ ការឆ្លើយតបរបស់ប្រទេសចិនចំពោះពន្ធគយបានបង្កើនល្បឿនពាណិជ្ជកម្ម និងការវិនិយោគរបស់ខ្លួនជាមួយទីផ្សារដែលកំពុងរីកចម្រើនផ្សេងទៀត។ *ប្រភព៖ World Economic Forum*

សេដ្ឋកិច្ចអាម៉េរិក និងសកលត្រូវបានព្យាករកើនឡើង OECD

អង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) បានតំឡើងកម្រិតការព្យាករណ៍កំណើនសេដ្ឋកិច្ចសកលរបស់ខ្លួនដល់ ៣,២% ក្នុងឆ្នាំ២០២៥ កើនឡើងពី ២,៩% នៃខែមិថុនាកន្លងទៅ ដោយលើកឡើងពីភាពធន់ខ្លាំងជាងការរំពឹងទុក ជាពិសេសប្រទេសដែលមានសេដ្ឋកិច្ចទីផ្សារកំពុងរីកចម្រើន។ ការរំពឹងទុកកំណើនរបស់អាម៉េរិកក៏ត្រូវបានដំឡើងពី ១,៦% ទៅ ១,៨%, ទោះបីជានៅតែស្ថិតនៅក្រោម ២,៨% កាលពីឆ្នាំ២០២៤ ក៏ដោយ។ កំណើននេះត្រូវបានគាំទ្រដោយការទិញទំនិញស្តុកផ្ទុកសម្រាប់ពេលខាងមុខ មុនពេលពន្ធគយឡើងខ្ពស់ ការវិនិយោគដែលទាក់ទងនឹងបញ្ញាសិប្បនិម្មិត (AI) ខ្លាំងនៅក្នុងសហរដ្ឋអាម៉េរិក និងការគាំពារថវិកាក្នុងប្រទេសចិន។ ទោះជាយ៉ាងណា OECD បានព្រមានអំពីហានិភ័យសំខាន់ៗ ដូចជាការកើនឡើងពន្ធគយ ភាពមិនច្បាស់លាស់នៃគោលនយោបាយ និងភាពតានតឹងពាណិជ្ជកម្មអាចប៉ះពាល់ដល់ការចំណាយ ទីផ្សារការងារ និងអតិផរណាជាដើម។ អតិផរណានៅក្នុងបណ្តាប្រទេសក្រុម២០ ត្រូវបានព្យាករណ៍ថាមានកម្រិត ៣,៤%, ខណៈអតិផរណារបស់អាម៉េរិកបានកែសម្រួលចុះមកត្រឹម ២,៧%។ ហានិភ័យនាពេលអនាគតរួមមាន ពន្ធគយបន្ថែម សម្ពាធសារពើពន្ធ និងការកំណត់តម្លៃទីផ្សារហិរញ្ញវត្ថុ។ *ប្រភព៖ CNBC*

ចិននឹងបញ្ឈប់ការទាមទារអត្ថប្រយោជន៍ពិសេសពី WTO ដែលធ្លាប់ធ្វើឱ្យអាម៉េរិកក្នាក់ចិត្ត

ប្រទេសចិនប្រកាសថានឹងឈប់ស្វែងសិទ្ធិ "កាពអនុគ្រោះ និងប្រព្រឹត្តកម្មពិសេស" ថ្មីនៅក្នុងការចរចាឬកិច្ចព្រមព្រៀងរបស់ WTO បច្ចុប្បន្ន និងអនាគត នេះបើយោងតាមនាយករដ្ឋមន្ត្រី Li Qiang ។ ការសម្រេចនេះជាការដកជម្លោះជាមួយអាម៉េរិក ហើយក៏ត្រូវបានស្វាគមន៍ដោយលោកស្រី អគ្គនាយិកា WTO។ យោងតាមមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រទេសចិននៅតែជាប្រទេសកំពុងអភិវឌ្ឍន៍ នឹងមិនផ្លាស់ប្តូរទេ ទោះបីជាខ្លួនមិនទទួល "កាពអនុគ្រោះ និងប្រព្រឹត្តកម្មពិសេស" ក៏ដោយ។ លោកនាយករដ្ឋមន្ត្រី Li Qiang បានប្រកាសពីការផ្លាស់ប្តូរនេះនៅទីក្រុងញូវយ៉កនៅមហាសន្និបាតអង្គការសហប្រជាជាតិ។ ការផ្លាស់ប្តូរនេះគឺមានសារៈសំខាន់នៅពេលដែលពន្ធគយរបស់អាម៉េរិកកើនឡើងខ្ពស់ ដែលជំរុញឱ្យប្រទេសចិនបង្វែរការនាំចេញទៅកាន់សេដ្ឋកិច្ចផ្សេងទៀត។ ក្រុមមន្ត្រីបានិយាយថា ការសម្រេចចិត្តនេះជាវិធានការការពារមួយ និងពង្រឹងប្រព័ន្ធពាណិជ្ជកម្មពហុភាគី និងបង្ហាញពីតួនាទីរបស់ប្រទេសចិនជាប្រទេសកំពុងអភិវឌ្ឍន៍ដ៏សំខាន់មួយ។ *ប្រភព៖ BLOOMBERG*

Tariffs Cause 'Unprecedented' Disruption to Global Trade Rules

The share of global trade under WTO terms has fallen to 72% from about 80%, marking the biggest disruption since World War Two, WTO chief Ngozi Okonjo-Iweala told. She warned tariffs could affect trade into 2026 as frontloaded goods run out. The WTO raised its in August trade growth forecast from 0.2% to 0.9%. Okonjo-Iweala voiced concern over U.S. plans to cut $29 million in WTO funding, though talks continue with USTR (the U.S. Trade Representative). She highlighted opportunities for WTO reform, noting China's openness on industrial policies. Members are working to streamline decision-making and address subsidies. ***Source: REUTERS***

WTO Agreement on Fisheries Subsidies Enters into Force

The WTO Agreement on Fisheries Subsidies has entered into force, committing members to curb harmful subsidies that deplete marine fish stocks. Adopted at the 12th Ministerial Conference in June 2022, it prohibits subsidies for illegal, unreported, and overfished fishing, including unregulated fishing. Director-General Ngozi Okonjo-Iweala hailed it as a "landmark for global trade governance" that protects livelihoods and promotes sustainability. Brazil, Kenya, Viet Nam, and Tonga completed acceptances, surpassing the two-thirds threshold. Members pledged to implement the Agreement, establish a WTO Fish Fund for capacity-building, and form a Committee on Fisheries Subsidies to increase transparency. The deal aims to restore fish stocks, secure food, and support hundreds of millions dependent on fisheries. ***Source: WTO***

Indonesia, EU Finalise Trade Deal After 9 Years of Talks

Indonesia and the European Union finalised their Comprehensive Economic Partnership Agreement (IEU-CEPA) after nine years of talks, aiming to boost trade and investment. The deal removes import duties on 98.5% of EU goods to Indonesia and allows Indonesian goods to enjoy zero tariffs in 90% of the EU market. It simplifies entry procedures for EU products including cars, milk powder, cheeses, meats, and chocolates. Trade between Indonesia and the EU is expected to double in the first five years. The agreement could increase investment and supply chain cooperation, including critical minerals and electric vehicle production. Non-tariff barriers, such as the EU Deforestation Regulation, remain a challenge for Indonesia's palm oil industry. ***Source: REUTERS***

China & US: How Can the World's Two Biggest Economies Have Such Different Problems?

The US and China face opposite cost-of-living trends. In China, a "pig cycle" of pork demand and oversupply has pushed food prices lower, contributing to deflation. Efforts to boost consumption include welfare spending, trade-in programs, and targeting the "silver economy." In the US, tariffs have created a "historical supply shock," raising prices for furniture, groceries, cars, and clothing, which is eroding household income. Businesses respond by lowering wages, hiring selectively, or not replacing staff. US tariffs aim to reshore manufacturing but mainly increase costs. Meanwhile, China's response to tariffs has accelerated its trade and investment with other emerging markets. ***Source: World Economic Forum***

U.S. and Global Growth Forecast Lifted By OECD

The OECD has raised its global growth forecast to 3.2% in 2025, up from June's 2.9%, citing stronger-than-expected resilience, especially in emerging-market economies. U.S. growth expectations were also lifted to 1.8% from 1.6%, though still below 2024's 2.8%. Growth was supported by front-loading ahead of higher tariffs, strong AI-related investment in the U.S., and fiscal support in China. However, the OECD warned of significant risks, as tariff increases, policy uncertainty, and trade tensions could affect spending, labor markets, and inflation. Headline inflation in G20 countries is projected at 3.4%, with U.S. inflation revised down to 2.7%. Future risks include further tariffs, fiscal pressures, and financial market repricing. ***Source: CNBC***

China to Stop Claiming Special WTO Benefits That Rankled US

China will stop seeking new "special and differential" rights in current and future WTO negotiations, according to Premier Li Qiang. The decision removes a point of contention with the U.S. and is welcomed by WTO Director General. China's status as a developing nation won't change, despite no longer being eligible for special treatment, according to a Ministry of Commerce official. Premier Li announced the change in New York at the United Nations General Assembly. The move is significant as higher U.S. tariffs push China to divert exports to other economies. Officials said the decision safeguards and strengthens the multilateral trading system and highlights China's role as a major developing country. ***Source: BLOOMBERG***

គោលនយោបាយសង្ខេប

ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងភាពធន់ខ្សែច្រវាក់តម្លៃផលិតកម្ម សកលនៅអាស៊ីប៉ាស៊ីហ្វិក និងអាស៊ាន[1]

(បកប្រែក្រៅផ្លូវការ)

ដោយ
សាស្ត្រាចារ្យ Shandre Mugan Thangavelu
វិទ្យាស្ថាន Jeffrey Cheah សម្រាប់អាស៊ីអាគ្នេយ៍ សាកលវិទ្យាល័យ Sunway

ថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០២៥

១. សេចក្តីផ្តើម

ភូមិសាស្ត្រសេដ្ឋកិច្ច គឺជាលក្ខណៈស្នូលនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងអាស៊ាន ហើយវាគឺជាជា ធម្មតាត្រូវបានគេរំលេចជាមជ្ឈភាពអាស៊ាន។ ក្របខ័ណ្ឌសំខាន់នៃភូមិសាស្ត្រសេដ្ឋកិច្ចគឺការផ្តល់អំណាចដល់ប្រទេសនានាដោយផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងតំបន់ជាមធ្យោបាយមួយដើម្បីគ្រប់គ្រងភូមិសាស្ត្រនយោបាយ និងសម្រេចបាននូវគោលដៅសេដ្ឋកិច្ចរបស់ខ្លួន។ វាត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងសមូហភាពនិងចក្ខុវិស័យរួម នៅក្នុងក្របខ័ណ្ឌតំបន់សម្រាប់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយហានិភ័យភូមិសាស្ត្រនយោបាយ និងអស្ថិរភាពក្នុងតំបន់។ ក្របខ័ណ្ឌនៃមជ្ឈភាពអាស៊ាននេះ គឺមូលដ្ឋានគ្រឹះនៃអាស៊ានសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចចាប់តាំងពីការបង្កើតអាស៊ានឡើងក្នុងឆ្នាំ១៩៦៧ និងចក្ខុវិស័យនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលបានផ្តល់ស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់អាស៊ាន។

គុណសម្បត្តិមួយចំនួននៃការទទួលយកភូមិសាស្ត្រសេដ្ឋកិច្ចដើម្បីគ្រប់គ្រងតំបន់និងភូមិសាស្ត្រនយោបាយសកល។ បណ្តាញសំខាន់មួយគឺការពង្រឹងទីផ្សារដោយផ្អែកលើគោលការណ៍ច្បាប់ពាណិជ្ជកម្ម ដែលកំណត់ក្របខ័ណ្ឌតួនាទីរបស់វិស័យឯកជន និងការទទួលស្គាល់គ្នាទៅវិញទៅមកផលប្រយោជន៍ក្នុងតំបន់ និងសកល។ ឧទាហរណ៍ ពាណិជ្ជកម្មសេរីទ្វេភាគី និងកិច្ចព្រមព្រៀងពហុភាគី (FTAs) កំណត់ការធ្វើសមាហរណកម្មតំបន់កាន់តែទូលំទូលាយ និងស៊ីជម្រៅ និងការប្តេជ្ញាចិត្តដើម្បីគ្រប់គ្រងភូមិសាស្ត្រនយោបាយក្នុងតំបន់ក្នុងក្របខ័ណ្ឌការធ្វើសមាហរណកម្ម។ ផលប៉ះពាល់នៃភូមិសាស្ត្រសេដ្ឋកិច្ចតាមរយៈក្របខ័ណ្ឌពាណិជ្ជកម្មក្នុងតំបន់ក្នុងក្របខ័ណ្ឌនៃពាណិជ្ជកម្មពហុភាគីមានភាពច្បាស់លាស់ដើម្បីគ្រប់គ្រងភាពមិនត្រឹមត្រូវនៃស្ថាប័ននៅក្នុងគោលនយោបាយ និងកាត់បន្ថយហានិភ័យគោលនយោបាយនៅក្នុងតំបន់។ វាក៏កំណត់ក្របខ័ណ្ឌសម្រាប់ការដោះស្រាយវិវាទសេដ្ឋកិច្ច ដូចជាការពង្រឹងកម្មសិទ្ធិបញ្ញា និងការអនុវត្តការជ្វេញជ្វូរមិនស្មោះត្រង់ ។ លើសពីនេះ វាក៏ដោះស្រាយវិវាទនៅក្នុងបញ្ហាសង្គមដូចជាបរិស្ថាន និងការប្រែប្រួលអាកាសធាតុ លំហូរកម្មករគ្មានជំនាញ និងបង្កើតក្របខ័ណ្ឌសម្រាប់បង្រួមគម្លាតអភិវឌ្ឍន៍រវាងសមាជិកបណ្តាប្រទេសនៅក្នុងសហគមន៍សង្គម-វប្បធម៌អាស៊ាន (ASCC) ដែលផ្តោតលើការកែលម្អគុណភាពស្តង់ដាជីវភាពរបស់ពលរដ្ឋអាស៊ាន លើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងជំរុញឱ្យមានភាពរឹងមាំអត្តសញ្ញាណអាស៊ានក្នុងវិស័យវប្បធម៌ ការអប់រំ និងការអភិវឌ្ឍសង្គម។

[1] The policy brief mainly cited from the following publications:

Thangavelu, S.M., Fukunari Kimura, D. Narjoko, 2024. 'Services and GVC Activities in ASEAN and ASEAN Economic Community: Next Stage of Growth in Global Value Chain', in Fukunari Kimura, Shandre Mugan Thangavelu, Christopher Findlay, and Lurong Chen (edits), 'Services Global Supply Chains in ASEAN and East Asia: Implications and Opportunities for Regional Integration', Springer, 2024.

Thangavelu, S. M., 2024. Chain reac ons: Regional coopera on can buffer global value chains against uncertainty. East Asia Forum Quarterly, 16(2), 34–36.

កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់អាសិប (RCEP) និងអាស៊ានបូកមួយ ជាមួយអូស្ត្រាលី ចិន ឥណ្ឌា កូរ៉េ និងនូវែលសេឡង់ ដែលធ្វើសមាហរណកម្មពាណិជ្ជកម្មក្នុងតំបន់ និងការវិនិយោគ ព្រមទាំងកំណត់រចនាសម្ព័ន្ធច្បាស់លាស់សម្រាប់ភូមិសាស្ត្រសេដ្ឋកិច្ច ដើម្បីកាត់បន្ថយការគ្រប់គ្រងភូមិសាស្ត្រនយោបាយក្នុងតំបន់។ វាគឺជាប្លុកពាណិជ្ជកម្មដ៏ធំបំផុតបានចូលជាធរមាននៅខែមករា ឆ្នាំ២០២២ រួមមានសមាជិកអាស៊ានទាំង១០ (ប្រ៊ុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម) និងប្រទេសក្នុងតំបន់ចំនួនប្រាំផ្សេងទៀតដែលអាស៊ានមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី-អូស្ត្រាលី ចិន ឥណ្ឌា ជប៉ុន កូរ៉េខាងត្បូង និងនូវែលសេឡង់។[23] ប្លុកពាណិជ្ជកម្មរួមចំណែកជិត ៣០% នៃប្រជាជនពិភពលោក ៣០% នៃផលិតផលក្នុងស្រុកសរុបសកល, និងជិត ២៨% នៃពាណិជ្ជកម្មសកលនៅក្នុងឆ្នាំ២០២២។ វាកំណត់របៀបវារៈដ៏សំខាន់មួយសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគក្នុងពាណិជ្ជកម្មសកលទាក់ទងនឹងការបើកទីផ្សារក្នុងស្រុក (តម្រូវការ) ការបញ្ចេញធនធានដ៏ធំសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ និងបង្កើតថាមវន្តខ្សែច្រវាក់តម្លៃក្នុងតំបន់ និងសកល (Kimura, Thangavelu និងNarjoko, 2022A)។ សរុបមក កិច្ចព្រមព្រៀងអាសិប RCEP អាចកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិន ដោយបង្កើតប្រសិទ្ធិភាពលទ្ធផលវិជ្ជមាន និងកំណើនក្នុងតំបន់ (Petri and Plummer, 2020)។

២. ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច

ខ្សែច្រវាក់តម្លៃផលិតកម្មសកល (GVCs) គឺជាយុទ្ធសាស្ត្រនៃកំណើនសេដ្ឋកិច្ចដ៏សំខាន់នៃអាស៊ីបូព៌ា និងអាស៊ាន។ ទោះយ៉ាងណាក៏ដោយ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ យើងកំពុងសង្កេតមើលការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ចកាន់តែធំ និងការចុះខ្សោយនៃសកម្មភាពខ្សែច្រវាក់តម្លៃនៅក្នុងតំបន់។ ជាការពិត វិបត្តិសេដ្ឋកិច្ច បានរារាំងដល់កំណើននៃខ្សែច្រវាក់តម្លៃទាំងកម្រិតតំបន់ កម្រិតសកល និងបង្កើតភាពមិនច្បាស់លាស់កាន់តែធំនៅក្នុងសកម្មភាពខ្សែច្រវាក់តម្លៃ (Constantinescu et al., 2020)។ យោងតាមរបាយការណ៍អភិវឌ្ឍន៍ពិភពលោក(២០២០) កំណើនខ្សែច្រវាក់តម្លៃសកលបានកើនឡើងដល់កំពូលក្នុងឆ្នាំ២០០៧ ហើយបានថយចុះជាមួយនឹងការចាប់ផ្តើមនៃវិបត្តិហិរញ្ញវត្ថុសកល (GFC)។ ក្រោយវិបត្តិហិរញ្ញវត្ថុសកល, ពាណិជ្ជកម្មសកលបានកត់ត្រាកំណើនធ្លាក់ចុះកាន់តែធ្ងន់ធ្ងរឡើងដោយការចាប់ផ្តើមនៃជំងឺរាតត្បាត Covid-19 (Reddy, Sasidharan, និង Thangavelu, 2024)។ លក្ខណៈទូទៅនៃវិបត្តិសកលទាំងនេះគឺភាពមិនប្រាកដប្រជានៃគោលនយោបាយសេដ្ឋកិច្ច (EPU ឆ្ពោះទៅមុខ) ដែលពាក់ព័ន្ធជាមួយពួកគេ (Baker et. al, 2016)។ ភាពមិនប្រាកដប្រជានេះនាំឱ្យមានការរង់ចាំនិងដោះស្រាយបញ្ហាសម្រាប់ក្រុមហ៊ុនដែលភាពមិនប្រាកដប្រជារបស់ក្រុមហ៊ុនបង្កឱ្យមានភាពអសកម្មក្នុងចំណោមក្រុមហ៊ុនដែលនាំទៅដល់ការកាត់បន្ថយកម្រិតនៃការវិនិយោគរបស់ពួកគេ (Bloom, 2009; Baker et. al, 2016)។ ភាពមិនប្រាកដប្រជាកាន់តែខ្លាំងគឺប៉ះពាល់ដល់កម្រិត ឬភាពធន់នៃសកម្មភាពខ្សែច្រវាក់តម្លៃនៅអាស៊ីបូព៌ា និងអាស៊ាន។

មានហេតុផលជាច្រើនសម្រាប់ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច។ ទី១ មានភាពមិនស្មើគ្នានៃផលប៉ះពាល់នៃពាណិជ្ជកម្ម និងការបើកចំហកំណើនសេដ្ឋកិច្ចនៅក្នុងតំបន់ និងរវាងបណ្តាលប្រទេស។ ភ័ស្តុតាងថ្មីៗបង្ហាញថាសេដ្ឋកិច្ចបើកចំហជួបប្រទះនឹងកំណើនខ្ពស់ ការពង្រីកវិសមភាពប្រាក់ឈ្នួលរវាងអ្នកជំនាញ និងអ្នកគ្មានជំនាញ ព្រមទាំងការបែងចែកជនបទ និងទីក្រុងកាន់តែធំ (Thangavelu et al. 2022B)។ ផលប៉ះពាល់មិនស្មើគ្នានៃបច្ចេកវិទ្យា និងពាណិជ្ជកម្មក៏បង្ហាញឱ្យឃើញផងដែររវាងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ភស្តុតាងថ្មីៗក៏បង្ហាញពីការចាប់យកបច្ចឹមប្រទេស(កំពុងអភិវឌ្ឍន៍) និងឧត្តរប្រទេស(អភិវឌ្ឍន៍) ការបង្រួមគម្លាតអភិវឌ្ឍន៍រវាងបច្ចឹមប្រទេសនិងឧត្តរប្រទេស។

[2] India has opted out of the agreement, but with some provisions to join RCEP in future.
[3] The ASEAN Framework for RCEP was adopted by the ASEAN Leaders during the 19th ASEAN Summit in November 2011 in Bali, Indonesia. The Joint Declaration of Ministers for launch of RCEP negotiations was done on 20 November 2012 in Phnom Penh, Cambodia during the 21st ASEAN Summit.

បញ្ហាដែលកំពុងកើតមាននៃការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ចទាក់ទងនឹងគោលនយោបាយសេដ្ឋកិច្ចភាពមិនប្រាកដប្រជា (EPU) នៅក្នុងការបើកចំហយុទ្ធសាស្ត្រសេដ្ឋកិច្ច កំពុងកាន់បង្ហាញកាន់តែតែច្បាស់ជាមួយសង្គ្រាមពាណិជ្ជកម្ម សហរដ្ឋអាម៉េរិក-ចិន និង យុទ្ធសាស្ត្រសម្ព័ន្ធភាព ដឹកនាំដោយសហរដ្ឋអាម៉េរិក និងអឺរ៉ុបជា មួយក្របខ័ណ្ឌសេដ្ឋកិច្ចឥណ្ឌូ-ប៉ាស៊ីហ្វិក ព្យាយាមផ្តាច់ខ្លួនពីសកម្មភាពបច្ចេកវិទ្យា និងសកម្មភាពខ្សែច្រវាក់តម្លៃសកលរបស់ប្រទេសចិន និងការផ្លាស់ប្តូរបច្ចេកវិទ្យា នៅអាស៊ីបូព៌ា តាមរយៈសកម្មភាពខ្សែច្រវាក់តម្លៃសកល។[4] ភាពមិនប្រាកដប្រជានៃយុទ្ធសាស្ត្រសម្ព័ន្ធមិត្តកំពុងបង្កើតភាពមិនប្រាកដប្រជាក្នុងការវិនិយោគទាក់ទងនឹងការផ្តាច់សកម្មភាពខ្សែច្រវាក់តម្លៃសកល នៃក្រុមហ៊ុនពហុជាតិសាសន៍ ជាពិសេសធនធានខាងក្រៅ (offshoring), ធនធានប្រទេសជិតខាង (nearshoring) និងធនធានសម្ព័ន្ធមិត្ត (friend-shoring) ។

លើសពីនេះ ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច តាមរយៈគោលនយោបានសេដ្ឋកិច្ចមិនប្រាកដប្រជាបានធ្វើឱ្យចុះខ្សោយនៃសកម្មភាព "មូលដ្ឋានទីផ្សារ" និង "គោលការណ៍ច្បាប់" ដែលជំរុញប្រសិទ្ធភាពនៃខ្សែច្រវាក់តម្លៃសកលនិងការធ្វើសមាហរណកម្មក្នុងតំបន់កាន់តែធំទូលាយ (Thangavelu, 2024) ។ មិនប្រាកដប្រជានៃគោលនយោបាយសេដ្ឋកិច្ចកំពុងកើនឡើងដែលធ្វើឱ្យថយចុះប្រសិទ្ធិភាពនៃការតភ្ជាប់បញ្ហាសនិងការតភ្ជាប់ឆ្ពោះទៅមុខ នៃសកម្មភាពខ្សែច្រវាក់តម្លៃសកល និងការរកើនឡើងនៃភាពងាយរងគ្រោះនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងសកម្មភាពក្រុមហ៊ុនក្នុងស្រុក។ ជាការពិត ឥទ្ធិពលគោលនយោបានសេដ្ឋកិច្ចមិនប្រាកដប្រជាទំនងជាត្រូវបានទទួលស្គាល់កាន់តែច្រើនប្រទេសដែលមានសកម្មភាពខ្សែច្រវាក់ផលិតកម្មខ្ពស់នៅក្នុងលក្ខខណ្ឌនៃការផ្លាស់ប្តូរច្រើន (ទ្វេដង) បរិវត្តកម្មនៃផលិតផលរបស់ពួកគេ ប្រៀបធៀបទៅនឹងប្រទេសដែលមានធនធានទាបនៅក្នុងខ្សែច្រវាក់តម្លៃក្នុងតំបន់និងសកល (Thangavelu, 2024) ។ ផលបច្ច័យនៃសម្ព័ន្ធភាពជាយុទ្ធសាស្ត្រអាចមានសារៈសំខាន់សម្រាប់ច្រើនទៀតសេដ្ឋកិច្ចអភិវឌ្ឍន៍និងកំពុងអភិវឌ្ឍន៍ប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ សិង្ហបុរី និងវៀតណាម។

ការសិក្សាថ្មីៗដោយ Ketan, Sasidharan, and Thangavelu (2024) គូសបញ្ជាក់ថា សកម្មភាពខ្សែច្រវាក់តម្លៃសកលនៅក្នុងអាស៊ីបូព៌ាកំពុងផ្លាស់ប្តូរដោយសារតែភាពមិនច្បាស់លាស់នៃគោលនយោបាយសេដ្ឋកិច្ច។ ផលប៉ះពាល់ដោយផ្ទាល់គឺខ្ពស់ជាងសម្រាប់ពាណិជ្ជកម្មនៅក្នុងខ្សែច្រវាក់តម្លៃសកល ដោយសារតែឥទ្ធិពលនៃទំនាក់ទំនងពាណិជ្ជកម្មកម្រិតមធ្យម និងសេវាកម្មនៅក្នុងសកម្មភាពច្រវាក់តម្លៃសកល។ មានផលប៉ះពាល់ដោយផ្ទាល់ទៅលើគំរូនៃការវិនិយោគ និងការសម្រេចចិត្តរបស់ក្រុមហ៊ុន នៅពេលដែលពួកគេអាចជ្រើសរើសការពន្យារពេលសកម្មភាពវិនិយោគរបស់ពួកគេ។ ការសិក្សាក៏បានគូសបញ្ជាក់ផងដែរថាពាណិជ្ជកម្មនិងគោលនយោបាយភាពមិនច្បាស់លាស់ដែលទាក់ទងនឹងពាណិជ្ជកម្មសកលនឹងមានឥទ្ធិពលផ្ទាល់ទៅលើការចូលរួម និងការចាកចេញរបស់ក្រុមហ៊ុនពីសកម្មភាពខ្សែច្រវាក់តម្លៃសកល ដោយសារការបង្កើតភាពមិនច្បាស់លាស់ខាងសេដ្ឋកិច្ចបន្ថែមទៀត (Ketan, Sasidharan, and Thangavelu, 2024).

៣. គោលនយោបាយដើម្បីសម្រាលផលពីការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច

